**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# សណ្ឋាគារ ជី អេវៀរី

## កិច្ចព្រមព្រៀងអំពីនីតិវិធីទូទាត់ជាមួយកម្មករនិយោជិត

ខ្ញុំបាទឈ្មោះ ជ្រោហ្វី ធិន គ្រិះ អាយុ ៤៤ឆ្នាំ ភេទប្រុស សញ្ជាតិ បារាំង ជាអ្នកគ្រប់គ្រងសណ្ឋាគារ **ជី អេវៀរី** ។ មានអាស័យដ្ឋាននៅភូមិ មណ្ឌល ॥ សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប។

**កម្មវត្ថុ** ៖ ផ្អាកដំណើការអាជីកម្ម សណ្ឋាគារជាបណ្ដោះអាសន្ន ក្រុមហ៊ុនយើងខ្ញុំស្នើសុំព្យួរកិច្ចសន្យាការងារកម្មករនិយោជិតចំនួន ៣២នាក់ (ស្រី១៧ នាក់) ក្នុងចំណោមកម្មករនិយោជិតសរុបចំនួន ៥០នាក់ (ស្រី ២២នាក់) រយៈពេល ៦០ថ្ងៃ ដោយគិតចាប់ពីថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២០ រហូតដល់ថ្ងៃទី១២ខែវិច្ឆិកា ឆ្នាំ២០២០។

**មូលហេតុ៖ ដោយសារបញ្ហាជំងឺផ្លូវដង្ហើមប្រភេទថ្មី Covid-19 ។**

ដោយយោងទៅលើសភាពនៃវិបត្តិជំងឺផ្លូវដង្ហើមប្រភេទថ្មី Covid-19 បានកំពុងរីករាលដាលខ្លាំងនៅលើសកល ដែលធ្វើឲ្យប៉ះពាល់យ៉ាងខ្លាំងដល់វិស័យទេសចរណ៍សកល ក៏ដូចជាវិស័យទេសចរណ៍ក្នុងព្រះរាជាណាចក្រកម្ពុជា ពិសេសក្នុងពេលថ្មីៗនេះ មានការផ្អាកនូវការហោះហើរពីតំបន់មួយទៅតំបន់មួយទៀតដើម្បីបង្ការនូវការឆ្លងរាលដាលនូវជំងឺ Covid-19។

យោងទៅតាម ស្របតាមស្មារតីនៃសេចក្ដីណែនាំលេខ០៤៥/២០ ចុះថ្ងៃទី១៧ ខែមេសាឆ្នាំ២០២០ ការបើកប្រាក់បៀវត្សដល់បុគ្គលិក សណ្ឋាគារជីអេវៀរី របស់យើងខ្ញុំនឹង បើកប្រាក់បៀវត្ស៥០% ជូនដល់បុគ្គលិកពីរដងក្នុងមួយខែ។

សៀមរាប ថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០២០

| | | |
|---|---|---|
| កញ្ញា ទិត មករា | កញ្ញា ទន់ សារ៉េន | លោក ជោហ្វ្រី ធិន គ្រិះ |
| តំណាងបុគ្គលិក | សាក្សីដោយ: | អ្នកគ្រប់គ្រងសណ្ឋាគារ |

ព្រះរាជាណាចក្រកម្ពុជា
សណ្ឋាគារ ជី អេវៀរី
THE AVIARY Hotel
KINGDOM OF CAMBODIA